**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ

## សូមគោរពជូន

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីចម្រើនជន្មាយុគម្រប់ ៧២ ឈានចូល ៧៣ ឆ្នាំ

***សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***

នាឱកាសដ៏មហាប្រសើរថ្លៃថ្លាពោរពេញដោយក្តីសោមនស្សរីករាយ **នៃពិធីចម្រើនជន្មាយុគម្រប់ ៧២ ឈានចូល ៧៣ ឆ្នាំ** ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៤ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំបាទនិងភរិយា សូមជូនសព្វសាធុការពរជ័យ សិរីមង្គល វិបុលសុខមហាប្រសើរ ជូន **សម្តេចតេជោ** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួនខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីដឹកនាំមាតុភូមិកម្ពុជាឱ្យមានសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍកាន់តែរីកចម្រើនបន្តទៀត។

ឆ្លៀតក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវមោទនភាព និងក្តីអំណរសាទរយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេច** ដែលកន្លងមកតែងបានយកចិត្តទុកដាក់ដឹកនាំប្រទេសជាតិឱ្យមានសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍលើគ្រប់វិស័យ។ ទន្ទឹមគ្នានេះ ថ្ងៃដ៏ពិសេសនៃពិធីចម្រើនជន្មាយុរបស់ **សម្តេច** ក៏ជាថ្ងៃដែលប្រជាជនកម្ពុជាទន្ទឹងរង់ចាំផងដែរ នោះគឺការចាប់ផ្តើមបើកការដ្ឋានសាងសង់នូវសំណង់ប្រវត្តិសាស្ត្រព្រែកជីក "ហ្វូណនតេជោ" ដែលនឹងផ្តល់ផលចំណេញយ៉ាងធំធេងដល់កម្ពុជា ទាំងផ្នែកសេដ្ឋកិច្ច និងជួយឱ្យកម្ពុជាពង្រឹងបាននូវឯករាជ្យភាពខាងនយោបាយលើការដឹកជញ្ជូនតាមផ្លូវទឹក។ សំណង់ប្រវត្តិសាស្ត្រមួយនេះ គឺជាកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំកំពូលៗ ជាពិសេស **សម្តេចតេជោ** ផ្ទាល់ ដែលតែងតែជំនះរាល់ឧបសគ្គនានា ប្រកបដោយឆន្ទៈដ៏មោះមុតដើម្បីបម្រើនូវឧត្តមប្រយោជន៍ជាតិ និងប្រជាជន។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំបាទនិងភរិយា សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមតាមជួយថែរក្សាការពារប្រោះព្រំ ជូន **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រីជាទីស្រឡាញ់ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ បញ្ញាញាណភ្លឺថ្លា ជន្មាយុយឺនយូរ សូមបានសម្រេចនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** ជានិច្ចនិរន្តរ៍កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។

ថ្ងៃអង្គារ ១០រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**